ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៣០៩៩ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុរួចមកឃើញថា ចាប់ពីថ្ងៃទី 30 ខែធ្នូ ឆ្នាំ 2014 ខាងមុខនេះតទៅ ជ្រលងសម្ពាធខ្ពស់ នឹងបង្កើនឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា បង្កឱ្យកម្រិតសីតុណ្ហភាពថយចុះ ធ្វើឱ្យអាកាសធាតុចុះត្រជាក់ជាថ្មីម្តងទៀត ។ យោងតាមការព្យាករណ៍ ចាប់ពីថ្ងៃទី 30 ខែធ្នូ ឆ្នាំ 2014 ដល់ថ្ងៃទី 04 ខែមករា ឆ្នាំ 2015 ស្ថានភាពសីតុណ្ហភាព នៅតាមបណ្តារាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម :

- តំបន់ជួរខ្នងភ្នំដងរែក ខេត្តឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង និងខេត្តប៉ៃលិន សីតុណ្ហភាពអប្បបរមានឹងធ្លាក់ចុះមកនៅក្នុងកម្រិតពី 13-17 $^{0}$C និងសីតុណ្ហភាពអតិបរមា មានពី 24-27 $^{0}$C ។
- រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម ក្រចេះ ព្រៃវែង និងខេត្តស្វាយរៀង សីតុណ្ហភាពអប្បបរមា មានពី 19-21 $^{0}$C និងសីតុណ្ហភាពអតិបរមា មានពី 27-29 $^{0}$C ។
- ខេត្តតាកែវ កោះកុង ព្រះសីហនុ កំពត និងខេត្តកែប សីតុណ្ហភាពអប្បបរមាមានពី 21-23 $^{0}$C និងសីតុណ្ហភាពអតិបរមា មានពី 30-32 $^{0}$C ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន **ជាពិសេសចំពោះវិរៈកងទ័ពដែលកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ** សូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ចំពោះបញ្ហាសុខភាពដែលអាចបង្កឱ្យមានជាជម្ងឺដង្កាត់ផ្សេងៗដែលបណ្តាលមកពីអាកាសធាតុចុះត្រជាក់នេះ ។

*រាជធានីភ្នំពេញ ថ្ងៃទី 28 ខែធ្នូ ឆ្នាំ2014*

**រដ្ឋមន្ត្រី**

**លឹម_គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh